ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ផែនការគ្រប់គ្រងកន្លែងឆេសាទសហគមន៍ជ្រោយស្វាយ

រយៈពេល ៣ឆ្នាំ (កញ្ញា ២០២៥ - សីហា ២០២៨)

ឈ្មោះសហគមនេសាទ ៖ ជ្រោយស្វាយ
ភូមិ ៖ ជ្រោយស្វាយ
កំពង់ស្តាំ
សារ៉ាយ
ឃុំ ៖ ជ្រោយស្វាយ
ស្រុក ៖ ស្រែអំបិល
ខេត្ត ៖ កោះកុង

រៀបចំដោយរដ្ឋបាលជលផល សហការជាមួយខណ្ឌរដ្ឋបាលជលផលកោះកុង

(គម្រោងជលផលសមុទ្រនិងតំបន់ឆ្នេរប្រកបដោយចីរភាព)

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ជ្រោយស្វាយ
រយៈពេល ៣ឆ្នាំ (កញ្ញា ២០២៥ - សីហា ២០២៨)

ឈ្មោះសហគមន៍នេសាទ ៖ ជ្រោយស្វាយ
ភូមិ ៖ ជ្រោយស្វាយ
កំពង់ស្តាំ
សារ៉ាយ
ឃុំ ៖ ជ្រោយស្វាយ
ស្រុក ៖ ស្រែអំបិល
ខេត្ត ៖ កោះកុង

រៀបចំដោយផ្ដួចផលផល សហការជាមួយខណ្ឌផ្ដួចផលផលកោះកុង (គម្រោងផលផលសមុទ្រនិងតំបន់ឆ្នេរគ្រប់គ្រងដោយសហគមន៍)

មាតិកា

ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

១- ស្ថានភាពទូទៅ.....១

២- អំពីប្រជាសាស្ត្រនិងសេដ្ឋកិច្ចសង្គម.....៦

ក- ប្រជាពលរដ្ឋ.....៦

ខ- មុខរបរ.....៣

៣- កន្លែងនេសាទសហគមន៍ និងធនធានដែលមាននៅក្នុងកន្លែងនេសាទសហគមន៍.....៣

ក- ទីតាំង.....៣

ខ- ដែននេសាទ.....៣

គ- តំបន់ដែលមានលទ្ធភាពបង្កើតកន្លែងអភិរក្ស.....៣

ឃ- ធនធានជលផល.....៤

៤- ការធ្វើនេសាទ.....៤

ក- អ្នកនេសាទ.....៤

ខ- ឧបករណ៍នេសាទ.....៤

គ- ការប៉ាន់ប្រមាណផលចាប់ប្រចាំឆ្នាំ.....៦

៥- ផែនការគ្រប់គ្រងសហគមន៍នេសាទ.....៧

ក- ទស្សនៈវិស័យ.....៧

ខ- គោលបំណង.....៧

គ- ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍.....៧

ផ្នែកទី១.ការអភិបាលរកិច្ចនិងការគ្រប់គ្រង.....៧

គ១- ផែនការសាងសង់ស្នាក់ការសហគមន៍នេសាទ.....៧

គ២- ផែនការប្រជុំប្រចាំខែនិងទិញសម្ភារអនុវត្តន៍ការងារគណៈកម្មការសហគមន៍នេសាទ.....៨

គ៣- ផែនការផ្សព្វផ្សាយនិងបណ្តុះបណ្តាល.....៨

គ៤- ផែនការប្រើប្រាស់ឧបករណ៍នេសាទ.....៩

គ៥- ផែនការទប់ស្កាត់បទល្មើសជលផល.....១០

គ៦- ផែនការកែលម្អកន្លែងនេសាទសហគមន៍.....១១

គ៧- ផែនការកំណត់និងរៀបចំកន្លែងអភិរក្សជលផលរបស់សហគមន៍នេសាទ.....១២

គ៨- ផែនការកំណត់និងរៀបចំស្ថានីយ៍ភ្ញាស់កូនក្តាមសេះរបស់សហគមន៍នេសាទ.....១២

គ៩- ផែនការគ្រប់គ្រងព្រៃកោកាង.....១៣

ផ្នែកទី២. សេដ្ឋកិច្ចនិងការអភិវឌ្ឍន៍សហគមន៍នេសាទ.....១៤

គ១០- ផែនការបង្កើតមុខរបរសមាជិកក្នុងសហគមន៍នេសាទ.....១៤

គ១១- ផែនការអភិវឌ្ឍន៍វារីវប្បកម្មក្នុងសហគមន៍នេសាទ.....១៥

គ១២- ផែនការបង្កើតកន្លែងទេសចរណ៍ធម្មជាតិរបស់សហគមន៍នេសាទ.....១៦

គ១៣- ផែនការបង្កើតក្រុមឥណទានដើម្បីបង្កើនមុខរបរ.....១៧

ផ្នែកទី៣. **ការចូលរួមរបស់ស្ត្រីនិងយុវជន ការកសាងភាពធន់នឹងការប្រែប្រួលអាកាសធាតុ**.....១៨

គ១៤- ផែនការផ្សព្វផ្សាយនិងជ្រើសរើសស្ត្រីនិងយុវជនចូលជាសមាជិកសហគមន៍នេសាទ.....១៨

គ១៥- ផែនការកសាងភាពធន់នឹងការប្រែប្រួលអាកាសធាតុ.....១៩

ផ្នែកទី៤. ការទំនាក់ទំនងនិងគៀងគរធនធាន.....១៩
គ១៦-ផែនការទំនាក់ទំនងនិងគៀងគរធនធាន.....១៩
គ១៧- ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍.....២០
ឃ- ផែនការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ.....២០
ង. ផែនការយុទ្ធសាស្ត្រ.....២១
តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ជ្រោយស្វាយ រយៈពេល៣ឆ្នាំ.....២២
តារាងពេលវេលាការងារ.....២៩

ផែនការគ្រប់គ្រង
កន្លែងសហគមន៍នេសាទ

១ ស្ថានភាពទូទៅ

សហគមន៍នេសាទជ្រោយស្វាយ ត្រូវបានបង្កើតឡើងដោយមហាសន្និបាតលើកដំបូងនៅថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០០៥ និងបានបោះឆ្នោតអាណត្តិទី៥ នៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២៤។ ហើយត្រូវបានចុះបញ្ជីជាផ្លូវការនិងទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមប្រកាសលេខ៥៨៤ ប្រក.កសក ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៧។

សហគមន៍នេសាទជ្រោយស្វាយ មានទីតាំងស្ថិតនៅភូមិជ្រោយស្វាយ ឃុំជ្រោយស្វាយ ស្រុកស្រែអំបិល ខេត្តកោះកុង។ មានសមាជិកសហគមន៍នេសាទសរុបចំនួន១៩២៦នាក់ ស្រី៩៦០នាក់ ក្នុងនោះចំនួនគ្រួសារសរុប ចំនួន៦៤២គ្រួសារ មានគណៈកម្មការចំនួន១១នាក់ ស្រី៣នាក់ និងមានក្រុមល្បាតចំនួន៧នាក់។

កន្លងមកនេះសហគមន៍នេសាទជ្រោយស្វាយ បានរៀបចំនិងអនុវត្តលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងរបស់សហគមន៍នេសាទ ចូលរួមកំណត់ព្រំប្រទល់ និងធ្វើផែនទីកន្លែងសហគមន៍នេសាទ បានរៀបចំបញ្ជីឈ្មោះសមាជិក បញ្ជីឈ្មោះគណៈកម្មការសហគមន៍នេសាទ និងបានរៀបចំរចនាសម្ព័ន្ធគ្រប់គ្រង បែងចែកតួនាទីនិងភារកិច្ចទទួលខុសត្រូវតាមការស្ម័គ្រចិត្តដោយមានការឯកភាពគ្នាក្នុងចំណោមគណៈកម្មការសហគមន៍នេសាទទាំងអស់។ ក្រៅពីនេះសហគមន៍នេសាទបានអនុវត្តសកម្មភាពសំខាន់ៗ រួមមានការចូលរួមប្រជុំ និងបិទប្រកាសផ្សព្វផ្សាយផែនទីកន្លែងសហគមន៍នេសាទ ការរៀបចំកន្លែងអភិរក្សជលផលរបស់សហគមន៍នេសាទ រៀបចំធនាគារក្តាមសេះ ការចាប់ផ្តើមអនុវត្តសកម្មភាពមុខរបរនិងទេសចរណ៍ជលផលរបស់សហគមន៍នេសាទ ចូលរួមប្រជុំផ្សព្វផ្សាយ និងវគ្គបណ្តុះបណ្តាលនានា ការរៀបចំក្រុមល្បាតរបស់សហគមន៍នេសាទ រួមសហការជាមួយសមត្ថកិច្ចជលផលអាជ្ញាធរមូលដ្ឋាន និងអង្គភាពពាក់ព័ន្ធដទៃទៀតក្នុងការចុះល្បាតទប់ស្កាត់ និងបង្ក្រាបបទល្មើសជលផលដែលកើតមាននៅក្នុងកន្លែងសហគមន៍នេសាទ។ រហូតមកដល់បច្ចុប្បន្ននេះ សហគមន៍នេសាទបានអនុវត្តសកម្មភាពតាមផែនការគ្រប់គ្រងរបស់ខ្លួន ដោយទទួលបានវឌ្ឍនភាពប្រកបដោយជោគជ័យក្នុងការកាត់បន្ថយសកម្មភាពបទល្មើសជលផលនានា។

ទោះបីជាទទួលបានលទ្ធផលដូចខាងលើក្តី សហគមន៍នេសាទជ្រោយស្វាយ នៅជួបប្រទះបញ្ហាប្រឈមនានាពាក់ព័ន្ធនឹងធនធានជលផលនិងអេកូឡូស៊ី ជីវភាពប្រជាពលរដ្ឋ និងការគ្រប់គ្រងមានដូចខាងក្រោម៖

-បញ្ហាប្រឈមពាក់ព័ន្ធនឹងធនធានជលផល និងអេកូឡូស៊ី រួមមាន ផលត្រីថយចុះ បរិមាណវារីសត្វថយចុះ ការបាត់បង់ប្រភេទត្រីធំៗ និងការបាត់បង់ទីជម្រក រួមមាន ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ការរំលោភដីព្រៃកោងកាង

- បញ្ហាប្រឈមពាក់ព័ន្ធនឹងជីវភាពប្រជាពលរដ្ឋ រួមមាន ខ្វះបច្ចេកទេសសមស្របធ្វើកសិកម្ម ខ្វះបច្ចេកទេសចិញ្ចឹមត្រីនិងចិញ្ចឹមសត្វ ខ្វះមុខរបរចិញ្ចឹមជីវិត ខ្វះសម្ភារ និងខ្វះពូជដំណាំ ការដាំដំណាំមិនបានផលល្អ ខ្វះប្រភពទឹក តម្លៃផលកសិកម្មស្ថិតនៅលើឈ្មួញកណ្តាល តម្លៃពលកម្មក្នុងតំបន់មានតម្លៃទាប ស្ត្រីខ្វះមុខរបរ ចំពោះស្ថានភាពយេដ៉ានៅមានកម្រិត ស្ថានភាពអនាម័យនៅមានកម្រិត ចំណេះដឹងនៅមានកម្រិត និងចំណាកស្រុក

-បញ្ហាប្រឈមពាក់ព័ន្ធនឹងការគ្រប់គ្រង រួមមាន សមត្ថភាពគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទនៅមានកម្រិត ការសហការជាមួយអ្នកពាក់ព័ន្ធនៅមានកម្រិត ខ្វះប្រភពថវិកា និងខ្វះសម្ភារមធ្យោបាយបង្ក្រាបបទល្មើសនេសាទ ជនល្មើសមិនខ្លាចក្រុមល្បាត អ្នកនេសាទខ្វះការយល់ដឹងពីច្បាប់ស្តីពីជលផល ខ្វះការចូលរួមពីប្រជាពលរដ្ឋក្នុងការអភិរក្សជលផលរបស់សហគមន៍នេសាទ និងការទប់ស្កាត់បទល្មើសជលផល។ សមាជិកសហគមន៍

នេសាទយល់ថាការងារជារបស់គណៈកម្មការសហគមន៍នេសាទ ជាតួនាទីរបស់បុរសចំណែកស្ត្រីមានតួនាទីជាអ្នកថែទាំគ្រួសារធ្វើការងារផ្ទះ និងលក់ដូរប៉ុណ្ណោះ ហើយទោះបីស្ត្រីមានការចូលរួមក្នុងកិច្ចប្រជុំនានាមានចំនួនច្រើនប៉ុន្តែការសម្រេចនៅមានកម្រិត។

ដូច្នេះទាមទារការរៀបចំកែសម្រួលឡើងវិញ នូវផែនការគ្រប់គ្រងកន្លែងសហគមន៍នេសាទជ្រោយស្វាយ ឆ្នាំ ២០២៤ ដល់ឆ្នាំ២០២៧ លេខ១១៥២ ជជ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២៤ ដោយរៀបចំផែនការសកម្មភាពសំខាន់ៗបន្ថែម និងថវិកាប៉ាន់ប្រមាណ ផ្តោតលើការអភិរក្សជលផល ការបង្កើតមុខរបរ ការចុះបញ្ជីនាវានេសាទ ការប្រមូលព័ត៌មាន រួមមាន ទូកនេសាទ ឧបករណ៍នេសាទ និងផលនេសាទជាដើម ព្រមទាំងការកាត់បន្ថយការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់។

២ អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

ក. ប្រជាសាស្ត្រ

ប្រជាពលរដ្ឋសរុបក្នុងតំបន់មានចំនួន ៤៨៧៥ នាក់ ស្រី ២២៣៨ នាក់ ក្នុងនោះមានចំនួន ១០៨៤ គ្រួសារ។ ប្រជាពលរដ្ឋក្នុងតំបន់ជាអ្នកកាន់សាសនាព្រះពុទ្ធ១០០%។

ក្នុងចំណោមសមាជិកគ្រួសារនៃសមាជិកសហគមន៍នេសាទទាំងអស់អ្នកមិនចេះអក្សរចំនួន ៥៨២ នាក់ ស្រី ៣០២ នាក់ កម្រិតថ្នាក់បឋមសិក្សាចំនួន ៩៨៥ នាក់ ស្រី ៥៤៥ នាក់ កម្រិតវិទ្យាល័យចំនួន ៣៦៧ នាក់ ស្រីចំនួន ៩៨នាក់ និងកម្រិតឧត្តម ៣២ នាក់ ស្រី ១៥ នាក់។ ១៩២៦នាក់ ស្រី៩៦០

- ចំនួនស្ត្រីមេម៉ាយក្នុងសហគមន៍នេសាទ មាន១៥នាក់
- ចំនួនបុរសពោះម៉ាយក្នុងសហគមន៍នេសាទ មាន៩នាក់
- ចំនួនជនពិការក្នុងសហគមន៍នេសាទ មាន៣២នាក់ ស្រី៩នាក់
- ចំនួនចាស់ជរាក្នុងសហគមន៍នេសាទ មាន១៧៦នាក់ ស្រី១៣៦នាក់
- ចំនួនកុមារកំព្រាក្នុងសហគមន៍នេសាទ មាន៣០នាក់ ស្រី២០នាក់
- ចំនួនអ្នកមានជំងឺរ៉ាំរ៉ៃក្នុងសហគមន៍នេសាទ មាន១៣នាក់ ស្រី៥នាក់។

ខ. មុខរបរ

មុខរបរសំខាន់ៗរបស់សមាជិកក្នុងសហគមន៍នេសាទនេះរួមមាន៖

- ធ្វើនេសាទ ចំនួន ២៨៥ គ្រួសារ
- ធ្វើស្រែ ចំនួន ១២៣ គ្រួសារ
- ធ្វើចំការ ចំនួន ៧២ គ្រួសារ
- ជាងជួសជុលម៉ូតូ ចំនួន ១០ គ្រួសារ
- ជាងជួសជុលទូក ចំនួន ៩គ្រួសារ
- ជាងសំណង់ ចំនួន ៥០ គ្រួសារ
- ជាងជួសជុលម៉ាញ៉ូទូរទស្សន៍ចំនួន ៥ គ្រួសារ
- អ្នកជួសជុលឧបករណ៍នេសាទចំនួន ៣២ គ្រួសារ
- លក់ដូរ ចំនួន ៣៧ គ្រួសារ
- ដឹកជញ្ជូនភ្ញៀវ ចំនួន ១៦ គ្រួសារ
- ចិញ្ចឹមសត្វ ចំនួន ៣៣ គ្រួសារ

- អ្នកកែច្នៃផលនេសាទ ចំនួន ៨៥ គ្រួសារ
- កម្មករលក់ពលកម្ម ចំនួន ១៥០ គ្រួសារ

ប្រាក់ចំណូលជាមធ្យមក្នុងគ្រួសារប្រចាំឆ្នាំមានចំនួន ៨ ៩២០ ០០០រៀល ។

៣ ទីតាំងសហគមន៍នេសាទ និងធនធានដែលមានក្នុងនេសាទសហគមន៍

ក. ទីតាំង

កន្លែងសហគមន៍នេសាទជ្រោយស្វាយ ជាតំបន់គ្រប់គ្រងផលផលសមុទ្រ មានកន្លែងនេសាទតាមឆ្នេរ នាទីព្រៃកោងកាង កន្លែងអភិរក្សផលផល កន្លែងវារីវប្បកម្ម វាលភក់ ដែលជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ស្ថិតនៅក្នុងភូមិនេសាទ ជ្រោយស្វាយខាងលិច ជ្រោយស្វាយខាងកើត កំពង់ស្តាំ ភ្នំស្រឡៅ សាវ៉ាយ និងភូមិឈើនាង ឃុំជ្រោយស្វាយ ស្រុកស្រែអំបិល ខេត្តកោះកុង។ សហគមន៍នេសាទជ្រោយស្វាយ មានទំហំ **១៣ ៤៨៣** ហិកតា និងមានកំណត់និយាមកាដូចមានចែងនៅ ក្នុងកិច្ចព្រមព្រៀងកន្លែងសហគមន៍នេសាទ។

សហគមន៍នេសាទជ្រោយស្វាយ មានព្រំប្រទល់ ៖

- ខាងជើងជាប់នឹងកន្លែងសហគមន៍នេសាទកោះខ្យង ឃុំជីខក្រោម ស្រុកស្រែអំបិល ខេត្តកោះកុង
- ខាងត្បូងជាប់នឹងភូមិថ្មរៀង ឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ
- ខាងកើតជាប់នឹងឃុំជ្រោយស្វាយ ស្រុកស្រែអំបិល ខេត្តកោះកុង
- ខាងលិចជាប់នឹងលំហសមុទ្រ។

ខ. ដែននេសាទ

កន្លែងសហគមន៍នេសាទជ្រោយស្វាយ មានលំហសមុទ្រចំនួន១ វាលភក់ចំនួន១ និងនាទីព្រៃកោងកាង ចំនួន១ គឺ៖

លំហសមុទ្រ	ទំហំ ១១៦០២ ហិកតា	នេសាទពេញមួយឆ្នាំ
វាលភក់	ទំហំ ១៨៣២ ហិកតា	នេសាទពេញមួយឆ្នាំ
នាទីព្រៃកោងកាង	ទំហំ ៩ ហិកតា	នេសាទពេញមួយឆ្នាំ ។

គ. តំបន់ដែលមានលទ្ធភាពបង្កើតកន្លែងអភិរក្សផលផល

សហគមន៍នេសាទជ្រោយស្វាយ បានសម្រេចក្នុងការបង្កើតកន្លែងអភិរក្សផលផលបីកន្លែងមាន ៥៣ ហិកតា ស្ថិតនៅក្នុងកន្លែងសហគមន៍នេសាទជ្រោយស្វាយ។ កន្លែងអភិរក្សផលផលនេះ ត្រូវបានធ្វើរៀបចំនិងគ្រប់គ្រងដោយសហគមន៍នេសាទ។

ឃ. ធនធានផលផល

ប្រទេសកម្ពុជា ធនធានផលផលដើរតួនាទីយ៉ាងសំខាន់ក្នុងសន្តិសុខស្បៀង និងសេដ្ឋកិច្ច ហើយធនធានផលផលផ្តល់ជាអាហារ និងមុខរបរនៃការចិញ្ចឹមជីវិតរបស់ប្រជានេសាទប្រចាំថ្ងៃ ជាពិសេសអ្នកនេសាទវ័យចាស់។ តាមការបង្ហាញពីសហគមន៍នេសាទត្រពាំងរពៅ បានឱ្យដឹងថា បច្ចុប្បន្នធនធានផលផលក្នុងសមុទ្រនៅទីនេះ មានស្ថានភាពល្អប្រសើរ ដោយសារមានការគ្រប់គ្រងល្អ។

ប្រភេទត្រីសមុទ្រ ៖ ត្រីក្តចិន ត្រីក្បាក ត្រីក្អុក ត្រីឆ្តង់ ត្រីក្រហម ត្រីផ្ងោង ត្រីឆ្លាម ត្រីបបែល ត្រីកាវ៉ា ត្រីប្រម៉ា ត្រីកាឡាំង ត្រីកន្តាំង ត្រីកន្ទុយរឹង ត្រីតុកតែ ត្រីអណ្តាតឆ្កែ ត្រីម្រេច ត្រីបាឃើ ត្រីអង្រែ ត្រីផ្នត់សមុទ្រ ត្រីឆ្លាធូ ត្រីអាំងកើយ ត្រីសេះ ត្រីសេក។

ប្រភេទវារីសត្វសមុទ្រ ៖ បង្គា បង្កង បង្កងកន្លុប បង្កងប៉ាក ក្តាមសេះ ក្តាមថ្ម ក្តាមជ័រ ក្តាមប្រង់ មឹក ត្រែងឈាម ងាវ ងាវភក់ ងាវហូល ងាវស អណ្តើក កន្ធាយ ប្រឡាំងកាស កាចរ អន្ទង់ ខ្ចឹង ផ្សោត ។ល។

ប្រភេទរុក្ខជាតិព្រៃកោងកាង និងវារីរុក្ខជាតិ៖ ដើមកោងកាងស្លឹកតូច ដើមកោងកាងស្លឹកធំ ដើមក្រញឹប ដើមអំពុះ ដើមអំពា ក្របាញញី ក្របាញឈ្មោល ដើមប៊ឹង ដើមប្រាសាក់ ដើមបើស ដើមឈើជ័រ ដើមក្លាយ ដើមឡេវអាវ ដើមចាក ដើមប្រង់ ដើមដូងទឹក ។ល។

៤. ការធ្វើនេសាទ

ក. អ្នកនេសាទ ៖

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន២៨៥នាក់ ស្រី ៦០នាក់
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទនៅក្នុងសហគមន៍១២៥នាក់
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍មានចំនួន១២១នាក់ ក្នុងមួយឆ្នាំ។

ខ. ឧបករណ៍នេសាទ ៖

- ឧបករណ៍នេសាទនិងទូកកាណូតរបស់សមាជិកសហគមន៍នេសាទ ៖

ប្រភេទឧបករណ៍	ឯកតា	ចំនួនគ្រួសារ	ចំនួនឧបករណ៍នេសាទ	ទំហំ/ប្រវែង	រដូវនេសាទ
មងត្រីចម្រុះ	ម៉ែត្រ	៨៥	៩០ម៉ែត្រ/គ្រួសារ	ក្រឡា៣,៥ស.មឡើង	ពេញមួយឆ្នាំ
មងបង្គា	ម៉ែត្រ	២៧	២៥០ម៉ែត្រ/គ្រួសារ	ក្រឡា៣,៥ស.មឡើង	ពីខែសីហាដល់ខែកញ្ញា
មងក្តាម	ម៉ែត្រ	២៥	២៥០ម៉ែត្រ/គ្រួសារ	ក្រឡា៨ស.មឡើង	ពេញមួយឆ្នាំ
មងត្រីកាម៉ុង	ម៉ែត្រ	៤៣	២៥០ម៉ែត្រ/គ្រួសារ	ក្រឡា៣,៥ស.មឡើង	ខែសីហាដល់ខែកញ្ញា
លបក្តាម	លប	៣៥	៥០០លប/គ្រួសារ	ក្រឡា៦ស.មឡើង	ពេញមួយឆ្នាំ
សន្ទូចរនង	ផ្លែ	១៩	១00-២00ផ្លែ/គ្រួសារ	ផ្លែលេខ១២-១៦	ពីខែមេសាដល់ខែវិច្ឆិកា
ធ្នាក់មឹកសំបកខ្យង	សំបក	៥១	១៥00សំបក/គ្រួសារ	-	ពេញមួយឆ្នាំ

(ស.ម = សង្ហីម៉ែត្រ, ម = ម៉ែត្រ)

ប្រភេទទូក កាណូត	ចំនួន	ចំណុះ	កំលាំងសេះ
ទូកមានម៉ាស៊ីនលើ	២៦៥គ្រឿង	៥00 - ២000គីឡូក្រាម	៦,៥ សេះ-២៤ សេះ
ទូកមានម៉ាស៊ីនបាត	២0គ្រឿង	២000 - ៤000 គីឡូក្រាម	១៦ សេះ-៣៥ សេះ

ឧបករណ៍នេសាទនិងទូកកាណូតរបស់អ្នកនៅក្នុងតំបន់ប៉ុន្តែមិនមែនជាសមាជិកសហគមន៍នេសាទ ៖

ឧបករណ៍នេសាទ	ឯកតា	ចំនួនគ្រួសារ	ចំនួនឧបករណ៍នេសាទ	ទំហំ/ប្រវែង	រដូវប្រើប្រាស់ឧបករណ៍ (ខែ...ដល់ខែ...)

មង់ត្រីចម្រុះ	ម៉ែត្រ	២៦	៩០ម៉ែត្រ/គ្រួសារ	ក្រឡា៣,៥ស.មឡើង	ពេញមួយឆ្នាំ
មង់បង្គា	ម៉ែត្រ	១៣	២៥០ម៉ែត្រ/គ្រួសារ	ក្រឡា៣,៥ស.មឡើង	ពីខែសីហាដល់ខែកញ្ញា
មង់ក្តាម	ម៉ែត្រ	១៥	២៥០ម៉ែត្រ/គ្រួសារ	ក្រឡា៨ស.មឡើង	ពីខែសីហាដល់ខែកញ្ញា
មង់ត្រីកាម៉ុង	ម៉ែត្រ	២៧	២៥០ម៉ែត្រ/គ្រួសារ	ក្រឡា៣,៥ស.មឡើង	ពីខែសីហាដល់ខែកញ្ញា
លបក្តាម	លប	៧	៥០០លប/គ្រួសារ	ក្រឡា៦ស.មឡើង	ពេញមួយឆ្នាំ
សន្ទូចរនង	ផ្លែ	៩	១០០-២០០ផ្លែ/គ្រួសារ	ផ្លែលេខ១២-១៦	ពីខែមេសាដល់ខែវិច្ឆិកា
ផ្នាក់មឹកសំបកខ្យង	សំបក	២៨	១៥០០សំបក/គ្រួសារ	-	ពេញមួយឆ្នាំ

ប្រភេទទូក កាណូត	ចំនួន	ចំណុះ	កំលាំងសេះ
ទូកមានម៉ាស៊ីនលើ	១២០ គ្រឿង	៥០០ - ២០០០គីឡូក្រាម	៦,៥ សេះ-២៤ សេះ
ទូកមានម៉ាស៊ីនបាត	៥ គ្រឿង	២០០០ - ៤០០០ គីឡូក្រាម	១៦ សេះ-៣៥ សេះ

ឧបករណ៍នេសាទនិងទូកកាណូតរបស់អ្នកមិនមែនជាសមាជិកសហគមន៍ដែលមកពីខាងក្រៅសហគមន៍៖

ប្រភេទឧបករណ៍	ឯកតា	ចំនួននាក់	ចំនួនឧបករណ៍នេសាទ	ទំហំ/ប្រវែង	រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....)
មង់ត្រីចម្រុះ	ម៉ែត្រ	៣៥	៩០ម៉ែត្រ/គ្រួសារ	ក្រឡា៣,៥ស.មឡើង	ពេញមួយឆ្នាំ
មង់បង្គា	ម៉ែត្រ	១២	២៥០ម៉ែត្រ/គ្រួសារ	ក្រឡា៣,៥ស.មឡើង	ពីខែសីហា ដល់ខែកញ្ញា
មង់ក្តាម	ម៉ែត្រ	២២	២៥០ម៉ែត្រ/គ្រួសារ	ក្រឡា៨ស.មឡើង	ពីខែសីហា ដល់ខែកញ្ញា
លបក្តាម	លប	២៥	៥០០លប/គ្រួសារ	ក្រឡា៦ស.មឡើង	ពេញមួយឆ្នាំ
សន្ទូចរនង	ផ្លែ	២៧	២៧សេះ	៥០០	ពីខែមេសា ដល់ខែវិច្ឆិកា

ប្រភេទទូក កាណូត	ចំនួន	ចំណុះ	កំលាំងសេះ
ទូកមានម៉ាស៊ីនលើ	២០ គ្រឿង	២000-៤000 គីឡូក្រាម	១៤សេះ- ២៤សេះ
ទូកមានម៉ាស៊ីនបាត	៣០ គ្រឿង	៤.000-១0.000គីឡូក្រាម	៤0សេះ-៨0សេះ

គ. ការប៉ាន់ប្រមាណផលចាប់បានប្រចាំឆ្នាំ

ប្រភេទផលនេសាទ	បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសារ (គ្រួសារអ្នកនេសាទ)		
	រដូវប្រាំង	រដូវវស្សា	សរុបប្រចាំឆ្នាំ
ត្រីគ្រប់ប្រភេទ	១៩៧៩ គីឡូក្រាម	១៧៤៥ គីឡូក្រាម	៣៧២៤ គីឡូក្រាម
បង្គា មឹក	១២៣៤ គីឡូក្រាម	១១២១ គីឡូក្រាម	២៣៥៥ គីឡូក្រាម
ក្តាម ខ្យង និងក្រែងឈាម	៩១៣ គីឡូក្រាម	៨0៥ គីឡូក្រាម	១៧១៨ គីឡូក្រាម
សរុប	៥0៩៤ គីឡូក្រាម	៤៥៥0 គីឡូក្រាម	៩៦៤៤ គីឡូក្រាម

៥-ផែនការគ្រប់គ្រងសហគមន៍នេសាទ

ក. ទស្សនៈវិស័យ ៖

សហគមន៍នេសាទជ្រោយស្វាយ មានទស្សនៈវិស័យចូលរួមគ្រប់គ្រងធនធានជលផលសមុទ្រប្រកបដោយសមធម៌ និងចីរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

ខ. គោលបំណង ៖

- ចូលរួមគ្រប់គ្រងដែននេសាទសមុទ្រ កន្លែងនេសាទគ្រួសារដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណី ឬសហគមន៍ធ្វើនេសាទកន្លែងសហគមន៍នេសាទ នាទីព្រៃកោងកាង និងនាទីទឹកជោរនាច
- ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តភាព និងធានាការបែងចែកផលប្រយោជន៍ ធនធានជលផលជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌
- ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍ តាមរយៈការអភិវឌ្ឍចម្រុះដោយមានការចូលរួម
- ដើម្បីឱ្យប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ និងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់លើធនធានធម្មជាតិ ។

គ. ផែនការគ្រប់គ្រងកន្លែងសហគមន៍នេសាទ

ផ្នែកទី១. ការអភិបាលកិច្ចនិងការគ្រប់គ្រង

គ១- ផែនការសាងសង់ស្នាក់ការសហគមន៍នេសាទ

ផែនការសាងសង់ស្នាក់ការសហគមន៍នេសាទ ចំណុចជាប់ផ្លូវចូលសហគមន៍នេសាទ ក្បែរវីសត ២០ម៉ែត្រ x ៤០ម៉ែត្រ និយាមកា 353887-1219110 ស្ថិតក្នុងភូមិជ្រោយស្វាយខាងលិច ឃុំជ្រោយស្វាយ ស្រុកស្រែអំបិល ខេត្តកោះកុង ត្រូវបានរៀបចំដូចខាងក្រោម៖

សកម្មភាព	លទ្ធផលរំពឹងទុក	ប៉ាន់ប្រមាណតម្លៃ (ដុល្លារ)	អ្នកចូលរួម	ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម	ថ្ងៃ ខែ ឆ្នាំ បញ្ចប់
ប្រជុំជាមួយអាជ្ញាធរមូលដ្ឋាន អង្គភាពនិងអ្នកពាក់ព័ន្ធ	-មានការចូលរួម -មានការគាំទ្រ	៥០០	សហគមន៍នេសាទ ស្ថាប័នពាក់ព័ន្ធ អង្គការដៃគូ	២០២៦	សីហា ២០២៨
សាងសង់ស្នាក់ការសហគន៍នេសាទ ទំហំ៨ម×១៥ម ធ្វើពីបេតុងរួមផ្សំគ្រឿងឈើ ប្រក់ក្បឿង រៀបចំបន្ទប់ជញ្ជាំងឥដ្ឋ និងមានបង្គន់អនាម័យ	-ស.ន មានកន្លែងធ្វើការ -មានលទ្ធភាពពេញលេញក្នុងការការពារ គ្រប់គ្រងកន្លែងសហគមន៍នេសាទ	៥០០០០		២០២៦	សីហា ២០២៨
បណ្តាញអគ្គីសនី	មានថាមពលអគ្គីសនីធ្វើការ	១៥០០		២០២៦	សីហា ២០២៨
រៀបចំប្រព័ន្ធទឹកស្អាត ស៊ីទែនជរ ២ ចំណុះ ៣ ៥០០លីត្រ	មានទឹកស្អាតប្រើប្រាស់	១២០០			
ទិញសម្ភារសហគមន៍នេសាទ (តុ ទូ ក្តារខៀន កៅអី កំព្យូទ័រ ព្រីនធើ LCD with Screen)	មានសម្ភារសម្រាប់ធ្វើការ	១៥៥០			

(ម = ម៉ែត្រ)

គ២- ផែនការសាងសង់អគារបង្កកផល ផលិតផលជលផលសមុទ្រ

ផែនការសាងសង់អគារបង្កកផល ផលិតផលជលផលសមុទ្រ នៅចំណុចជាប់ផ្លូវផែ សហគមន៍នេសាទ ទំហំ ២៩ម៉ែត្រ x ៤០ម៉ែត្រ ស្ថិតក្នុងភូមិជ្រោយស្វាយខាងលិច ឃុំជ្រោយស្វាយ ស្រុកស្រែអំបិល ខេត្តកោះកុង ត្រូវបាន រៀបចំដូចខាងក្រោម៖

សកម្មភាព	លទ្ធផលរំពឹងទុក	ប៉ាន់ប្រមាណតម្លៃ (ដុល្លារ)	អ្នកចូលរួម	ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម	ថ្ងៃ ខែ ឆ្នាំ បញ្ចប់
ប្រជុំជាមួយអាជ្ញាធរមូលដ្ឋាន អង្គភាព និងអ្នកពាក់ព័ន្ធ	-មានការចូលរួម -មានការគាំទ្រ	៥00	សហគមន៍នេសាទ ស្ថាប័នពាក់ព័ន្ធ អង្គការដៃគូ	កញ្ញា ២០២៥	សីហា ២០២៨
រៀបចំឯកសារគាំទ្រពីអាជ្ញាធរ រដ្ឋបាលជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងស្ថានទូតជប៉ុន		៥00			
សាងសង់អគារបង្កកផល ផលិតផលជលផលសមុទ្រ ទំហំ២៤មx៣៥ម ធ្វើពីបេតុង គ្រឿងដែក ប្រក់ក្បឿង រៀបចំបន្ទប់បង្កក ជញ្ជាំងឥដ្ឋ បន្ទប់ទឹក និងបង្គន់អនាម័យ	-ស.ន មានអគារបង្កកផលផលិតផលជលផលសមុទ្រ -មានលទ្ធភាពពេញលេញក្នុងការកែច្នៃ និងវេចខ្ចប់	៨0000		កញ្ញា ២០២៥	សីហា ២០២៨
តបណ្តាញអគ្គីសនី	មានថាមពលអគ្គីសនីធ្វើការ	១៥00		កញ្ញា ២០២៥	សីហា ២០២៨
តនិងរៀបចំប្រព័ន្ធទឹកស្អាត	មានទឹកស្អាតប្រើប្រាស់	២0000			
បំពាក់សម្ភារបង្កក និងកែច្នៃ	មានសម្ភារសម្រាប់ធ្វើការ	៣0000			

(ម = មែត្រ)

គ៣- ផែនការប្រជុំនិងទិញសម្ភារអនុវត្តន៍ការងាររបស់គណៈកម្មការសហគមន៍នេសាទ

ផែនការប្រជុំនិងទិញសម្ភារអនុវត្តន៍ការងារគណៈកម្មការសហគមន៍នេសាទ ត្រូវបានរៀបចំដូចខាងក្រោម ៖

សកម្មភាព	លទ្ធផលរំពឹងទុក	ប៉ាន់ប្រមាណតម្លៃ(ដុល្លារ)	អ្នកចូលរួម	ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម	ថ្ងៃ ខែ ឆ្នាំ បញ្ចប់
ប្រជុំគណៈកម្មការសហគមន៍នេសាទ សប្តាហ៍ទី១នៃខែរៀងរាល់ខែឬត្រីមាស	-របាយការណ៍លទ្ធផលសម្រេចបានក្នុងខែ -មានផែនការណ៍អនុវត្តន៍បន្ត -លើកបញ្ហាប្រឈម តម្រូវការ	៧២0	-គណៈកម្មការ -ក្រុមល្បាត	កញ្ញា ២០២៥	សីហា ២០២៨
ចូលរួមប្រជុំជាមួយអាជ្ញាធរឃុំ ស្រុក ឬអង្គភាពពាក់ព័ន្ធ	-ទទួលព័ត៌មាន និងផ្តល់របាយការណ៍លទ្ធផលការងារ -បញ្ចូលផែនការណ៍ជាមួយផែនការអភិវឌ្ឍន៍ឃុំ -មានដំណោះស្រាយ	៦៥0	-អាជ្ញាធរឃុំ -គណៈកម្មការ	កញ្ញា ២០២៥	សីហា ២០២៨
ចូលរួមប្រជុំជាមួយបណ្តាញស.ន ថ្នាក់ស្រុក ឬថ្នាក់ខេត្ត			-អាជ្ញាធរស្រុក/ខេត្ត -បណ្តាញស.ន		

ចុះប្រជុំដើម្បីជម្រុញការចុះបញ្ជីទូកម៉ាស៊ីន ដោយសហការជាមួយអាជ្ញាធរមូលដ្ឋាន និងជំនាញពាក់ព័ន្ធ ជាប្រចាំ	- ចុះបញ្ជីទូកម៉ាស៊ីនគ្រប់ចំនួន - ទូកម៉ាស៊ីនធ្វើនេសាទបានដាក់ប្រព័ន្ធតាមដាន -បទល្មើសជលផលថយចុះ	៦០០	គណៈកម្មការអាជ្ញាធរមូលដ្ឋានជំនាញជលផលស្ថាប័នពាក់ព័ន្ធ	កញ្ញា ២០២៥	សីហា ២០២៨
ចុះអនុវត្តន៍សកម្មភាពការប្រមូលព័ត៌មាន ការកត់ត្រាទូកនេសាទ ឧបករណ៍នេសាទ និងផលចាប់ត្រី	-មានព័ត៌មានច្បាស់លាស់ -រៀបចំផែនការបានត្រឹមត្រូវ -ការគ្រប់គ្រងស.នបានល្អ	៩០០	-គណៈកម្មការ -សមាជិកស.ន	កញ្ញា ២០២៥	សីហា ២០២៨
-សម្ភារការិយាល័យ - LCD with Screen -ទិញក្រដាស់ បិច ព្រីនឯកសារ កូពី -ការទំនាក់ទំនង	មានសម្ភារការិយាល័យសម្រាប់ប្រើប្រាស់	២០០០	គណៈកម្មការ	កញ្ញា ២០២៥	សីហា ២០២៨

(ស.ន = សហគមន៍នេសាទ)

ក៤- ផែនការផ្សព្វផ្សាយនិងបណ្តុះបណ្តាល

ផែនការផ្សព្វផ្សាយ និងបណ្តុះបណ្តាល ត្រូវបានរៀបចំឡើង ដើម្បីពង្រឹងសមត្ថភាពដល់សហគមន៍នេសាទ មានដូចខាងក្រោម ៖

សកម្មភាព	លទ្ធផលរំពឹងទុក	ប៉ាន់ប្រមាណតម្លៃ(ដុល្លារ)	អ្នកចូលរួម	ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម	ថ្ងៃ ខែ ឆ្នាំ បញ្ចប់
ផែនការផ្សព្វផ្សាយ					
ប្រជុំផ្សព្វផ្សាយស្តីពី ៖ -ច្បាប់ជលផល ឯកសារគតិយុត្តិនានាពាក់ព័ន្ធនឹងស.ន -លក្ខន្តិក: បទបញ្ជាផ្ទៃក្នុងស.ន និងផែនការគ្រប់គ្រងកន្លែងសហគមន៍នេសាទ -ការរៀបចំនិងទុកដាក់សម្រាម -បទពិសោធន៍នានាទទួលបាន	-សមាជិកសហគមន៍នេសាទ និងអ្នកខាងក្រៅមានការយល់ដឹង និងអនុវត្តតាម -សមាជិកនិងប្រជាពលរដ្ឋចូលរួមអនុវត្តតាមផែនការ និងវិធានច្បាប់នានាដែលបានផ្សព្វផ្សាយ -ផលត្រីនៅក្នុងសហគមន៍មានការកើនឡើងប្រជាពលរដ្ឋអាចរកត្រីបានច្រើននាំឱ្យជីវភាពធូរធារ	២៥៨០	គណៈកម្មការ, សមាជិកស.ន និងអ្នកក្រៅស.ន អាជ្ញាធរមូលដ្ឋានជំនាញជលផល, អង្គការដៃគូ	កញ្ញា ២០២៥	សីហា ២០២៨
បិទផ្សាយឯកសារ ១ដង/ឆ្នាំ		១៦០		កញ្ញា ២០២៥	សីហា ២០២៨
-ចែកចាយឯកសារផែនការប្រើប្រាស់ឧបករណ៍ដល់អ្នកនេសាទ១ដង/ឆ្នាំ -ចែកចាយឯកសារនានា		៤៥០			
ផ្សព្វផ្សាយដល់សមាជិកសហគមន៍នេសាទ ដើម្បីចុះបញ្ជីទូកម៉ាស៊ីន	សមាជិកសហគមន៍នេសាទបានចុះបញ្ជីទូកម៉ាស៊ីន តាមច្បាប់	៤៥០	គណៈកម្មការនិងសមាជិកស.ន អាជ្ញាធរមូលដ្ឋាន	កញ្ញា ២០២៥	សីហា ២០២៨

ផែនការបណ្តុះបណ្តាល					
វគ្គបណ្តុះបណ្តាលពីរបៀបរៀបចំលិខិតរដ្ឋបាល ៖ -កំណត់ហេតុ -របាយការណ៍ -គម្រោងស្នើសុំថវិកា -គម្រោងថវិកា និងការគ្រប់គ្រងថវិកាសហគមន៍នេសាទ	គណៈសហគមន៍នេសាទ សមាជិកស.ន ប្រជាពលរដ្ឋ សិស្ស និស្សិតបានយល់ដឹង និងអាចអនុវត្តន៍បាន ក្នុងការងារជាក់ស្តែង	១៥០០	គណៈកម្មការនិង សមាជិកស.ន អាជ្ញាធរមូលដ្ឋាន	កញ្ញា ២០២៥	សីហា ២០២៨
វគ្គបណ្តុះបណ្តាលពីកំប្យូទ័រ	គណៈសហគមន៍នេសាទ(២នាក់)	៣៦០	គណៈកម្មការស.ន		
វគ្គបណ្តុះបណ្តាលវិធីសាស្ត្រការប្រមូលព័ត៌មាន ដោយការកត់ត្រា ទូកនេសាទ ឧបករណ៍នេសាទ និងផលចាប់ត្រី	គណៈកម្មការសហគមន៍នេសាទ បានយល់ដឹង និងអាចអនុវត្តន៍បានក្នុងការងារជាក់ស្តែង	៨០០	គណៈកម្មការនិង សមាជិកស.ន អាជ្ញាធរមូលដ្ឋាន	កញ្ញា ២០២៥	សីហា ២០២៨
វគ្គបណ្តុះបណ្តាលពីការសម្របសម្រួលនិងដោះស្រាយទំនាស់		៥០០	គណៈកម្មការជំនាញជលផល	កញ្ញា ២០២៥	សីហា ២០២៨
បណ្តុះបណ្តាលពីសហគ្រិនភាពដល់គណៈការនិងសមាជិកស.ន	ស្ត្រីមានលទ្ធភាពនិងសមត្ថភាពក្នុងការប្រកបមុខរបរ	៥០០	គណៈកម្មការសហគ្រិនខ្មែរ	កញ្ញា ២០២៥	សីហា ២០២៨

(ស.ន = សហគមន៍នេសាទ)

គ.៥- ផែនការប្រើប្រាស់ឧបករណ៍នេសាទ

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងសហគមន៍នេសាទ គឺរៀបចំឡើងដោយគិតគូរនូវប្រភេទតំបន់គ្រប់គ្រងជលផល ប្រភេទ ទំហំ ប្រវែង និងចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ ។

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងសហគមន៍នេសាទ ត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

ឈ្មោះ/ទីតាំងកន្លែងនេសាទ	ពេលវេលាធ្វើនេសាទ	ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ			ផ្សេង
		ប្រភេទ	ទំហំ/ប្រវែង	ចំនួន	
កន្លែងនេសាទសហគមន៍ជ្រោយស្វាយ	ពេញរដូវនេសាទ	មងត្រីក្បក	ក្រឡា ៣,៥ស.មឡើង	៥០០ម/គ្រួសារ	គណៈកម្មការ និងសមាជិកសហគមន៍នេសាទ
		មងត្រីឆ្កង	ក្រឡា ១០ ស.មឡើង	៥០០ម/គ្រួសារ	
		មងត្រីក្អក	ក្រឡា ៩ ស.មឡើង	៥០០ម/គ្រួសារ	
		មងត្រីអណ្តាតឆ្កែ	ក្រឡា ៥,៥ ស.មឡើង	៥០០ម/គ្រួសារ	
		មងត្រីចាប	ក្រឡា ៦ ស.មឡើង	៥០០ម/គ្រួសារ	
		មងបបែល	ក្រឡា ១៥ ស.មឡើង	៥០០ម/គ្រួសារ	
		មងត្រីព្រលួស	ក្រឡា ២,៥ ស.មឡើង	៥០០ម/គ្រួសារ	
		មងត្រីប្រឌុប ឬត្រីកាម៉ុយ	ក្រឡា ៣,៥ ស.មឡើង	៥០០ម/គ្រួសារ	
		មងត្រីកាប៉ាស់ ឬត្រីដូរអង្ករ	ក្រឡា ១០ ស.មឡើង	៥០០ម/គ្រួសារ	
		មងត្រីក្សាន្ត	ក្រឡា ៣ ស.មឡើង	៥០០ម/គ្រួសារ	
		មងត្រីផ្ងោង	ក្រឡា ២,៥ ស.មឡើង	៥០០ម/គ្រួសារ	

កន្លែងនេសាទសហគមន៍ជ្រោយស្វាយ	ពេញរដូវនេសាទ	មងត្រីកន្តាំង	ក្រឡា ៤ ស.មឡើង	៥០០ម/គ្រួសារ	គណៈកម្មការ និងសមាជិកសហគមន៍នេសាទ
		មងក្តាម	ក្រឡា ៨ ស.មឡើង	៥០០ម/គ្រួសារ	
		មងប៉ាកាំង ឬបង្គងកន្ទុប	ក្រឡា ៣ ស.មឡើង	៥០០ម/គ្រួសារ	
		មងត្រីកាម៉ុង	ក្រឡា ៣,៥ ស.មឡើង	៥០០ម/គ្រួសារ	
		មងត្រីកន្ទុយរឹង	ក្រឡា ៤,៨ ស.មឡើង	៥០០ម/គ្រួសារ	
		មងត្រីកាវ៉ាវ	ក្រឡា ៧ ស.មឡើង	៥០០ម/គ្រួសារ	
		មងបេកា	ក្រឡា ៨ ស.មឡើង	៣០០ម/គ្រួសារ	
		មងត្រីសំប៉ាន	ក្រឡា ១០ ស.មឡើង	៥០០ម/គ្រួសារ	
		មងត្រីគូន	ក្រឡា ២,៥ ស.មឡើង	៥០០ម/គ្រួសារ	
		មងបង្គា១ជាន់	ក្រឡា ៣,៥ ស.មឡើង	៥០០ម/គ្រួសារ	
		មងបង្គា៣ជាន់	ក្រឡា ៣,៥ ស.មឡើង	៣០០ម/គ្រួសារ	
		មងហ៊ុម	ក្រឡា ៣ ស.មឡើង	១០០ម/គ្រួសារ	
		លបមឹក	ក្រឡា ៦ ស.មឡើង	៨០លប/គ្រួសារ	
		លបក្តាម	ក្រឡា ៦ ស.មឡើង	៨០លប/គ្រួសារ	
		លបបង្គា	ក្រឡា ៦ ស.មឡើង	៨០លប/គ្រួសារ	
		លបខ្យង	ក្រឡា ៦ ស.មឡើង	៨០លប/គ្រួសារ	
		លបត្រី	ក្រឡា ៦ ស.មឡើង	២០លប/គ្រួសារ	
		លបត្រីតុកកែ	ក្រឡា ៦ ស.មឡើង	២០លប/គ្រួសារ	
		លបប្រឹសច្រើន/កន្ទុយកណ្តុរ	ក្រឡា ៣ ស.មឡើង	២០លប/គ្រួសារ	
		អួនត្រីស	ក្រឡា ២,៥ ស.មឡើង	១០០ម/គ្រួសារ	
		អួនត្រីកាឡែងតែង	ក្រឡា ១,៥ ស.មឡើង	១០០ម/គ្រួសារ	
		អួនហ៊ុមកៀនច្រាំង	ក្រឡា ៣ ស.មឡើង	១០០ម/គ្រួសារ	
		អួនខូវ ឬមងខូវ	ក្រឡា ៣ ស.មឡើង	១០០ម/គ្រួសារ	
		អួនកេវ ឬមងកេវ	ក្រឡា ៣ ស.មឡើង	១០០ម/គ្រួសារ	
		សន្ទូចរនងត្រី	មិនកំណត់	៥០០ផ្លែ/គ្រួសារ	
		សន្ទូចរនងបបែល	មិនកំណត់	៥០០ផ្លែ/គ្រួសារ	
		សន្ទូចរនងមឹក	ផ្លែលេខ១-៤	៥០០ផ្លែ/គ្រួសារ	
		រនងធ្នាក់មឹក	-	៥០០គ្រ/គ្រួសារ	
		សន្ទូចត្រីបេកា	-	៥០០ផ្លែ/គ្រួសារ	
		សន្ទូចមឹក	ផ្លែលេខ១-៤	៥០០ផ្លែ/គ្រួសារ	
		សន្ទូចដៃ	មិនកំណត់	មិនកំណត់	
		សន្ទូចបបក់	មិនកំណត់	មិនកំណត់	
		ឈិបរុញដោយដៃ	ក្រឡា ១,៥ ស.មឡើង	មិនកំណត់	
		រាវគ្រែងឈាម	មិនកំណត់	មិនកំណត់	
		រាវងាវកក់	មិនកំណត់	មិនកំណត់	
		លូកក្តាមថ្ម ជ័រ	មិនកំណត់	មិនកំណត់	
		សំណាញ់	ក្រឡា ១,៥ ស.មឡើង	មិនកំណត់	

(ស.ម = សង្ហីម៉ែត្រ, ម = ម៉ែត្រ, គ្រ = គ្រាប់)

ក៦-ផែនការទប់ស្កាត់បទល្មើសជលផល

ផែនការចុះទប់ស្កាត់បទល្មើសជលផល ត្រូវបានរៀបចំដូចខាងក្រោម ៖

សកម្មភាព	លទ្ធផលរំពឹងទុក	ប៉ាន់ប្រមាណតម្លៃ(ដុល្លារ)	អ្នកចូលរួម	ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម	ថ្ងៃ ខែ ឆ្នាំ បញ្ចប់
ផ្សព្វផ្សាយ៖ -តាមមេភ្រូ ៣ថ្ងៃ/ឆ្នាំ -បិទឯកសារ ១ដង/ឆ្នាំ -ចែកឯកសារ -ប្រជុំផ្សព្វផ្សាយ ១ដង/ឆ្នាំ កញ្ញា/រៀងរាល់ឆ្នាំ	-មានការយល់ដឹងពីការប្រើប្រាស់ឧបករណ៍នេសាទនិងសារៈសំខាន់នៃធនធានជលផល -មានការយល់ដឹងពីការគ្រប់គ្រងសហគមន៍នេសាទ -កាត់បន្ថយការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់	១៥៦០	សហគមន៍នេសាទ អាជ្ញាធរមូលដ្ឋាន ជំនាញជលផល អង្គការដៃគូ	កញ្ញា ២០២៥	សីហា ២០២៨
ប្រជុំពិភាក្សាគណៈកម្មការសហគមន៍រៀបចំផែនការប្រចាំខែ ឬឆមាស(មករានិង កញ្ញា/រៀងរាល់ឆ្នាំ)	-គណៈកម្មការទទួលបាននូវបទពិសោធន៍ល្អៗ -មានផែនការសមស្របជាក់លាក់ដើម្បីចុះអនុវត្តន៍ការងារ	៣៦០	សហគមន៍នេសាទ អាជ្ញាធរមូលដ្ឋាន អង្គភាពពាក់ព័ន្ធ	កញ្ញា ២០២៥	សីហា ២០២៨
អនុវត្តន៍ផែនការ៖ (រៀបចំកំលាំងចុះបង្ក្រាបដល់ទីកន្លែងដោយទំនាក់ទំនងនិងសហការជាមួយ អាជ្ញាធរមូលដ្ឋាន អង្គភាពពាក់ព័ន្ធនិងអង្គការដៃគូ) (៤ដង/ខែ = ១៤៤/ដង)	-បទល្មើសនេសាទថយចុះនិងឈានទៅលុបបំបាត់ ទាំងស្រុង -ធនធានជលផលកើនឡើង -ជីវភាពសមាជិកសហគមន៍នេសាទធូរធារ	១០៣៦៨	សហគមន៍នេសាទ អាជ្ញាធរមូលដ្ឋាន ជំនាញជលផល ស្ថាប័នពាក់ព័ន្ធ អង្គការដៃគូ	កញ្ញា ២០២៥	សីហា ២០២៨
មធ្យោបាយនិងសម្ភារ -សាំង និងប្រេងបាត -អាវ ស្បែកជើង មួក អាវភ្លៀង អាវពោង ពិល អាយកូម ម៉ាស៊ីនថត កែវយឺត កាតទូរស័ព្ទ	មានលទ្ធភាពចុះល្បាតដោយមានប្រសិទ្ធិភាព	៣៣៨៦	សហគមន៍នេសាទ អាជ្ញាធរមូលដ្ឋាន ជំនាញជលផល អង្គការដៃគូ	កញ្ញា ២០២៥	សីហា ២០២៨
ទិញអូប័រនិងម៉ាស៊ីនកម្លាំង ៤០សេះ ចំនួន១គ្រឿង	មានមធ្យោបាយចុះល្បាត	៦០០០	សហគមន៍នេសាទ អាជ្ញាធរមូលដ្ឋាន ជំនាញជលផល អង្គការដៃគូ	កញ្ញា ២០២៥	សីហា ២០២៨
កៀងគរថវិកាក្នុងការឧបបត្ថម្ភ ឬបដិភាគដល់ប្រជានេសាទដែលឈប់ឬផ្លាស់ប្តូរការប្រើឧបករណ៍នេសាទខុសច្បាប់ ដែលបំផ្លិចបំផ្លាញ	កាត់បន្ថយការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់	៥០០០	សហគមន៍នេសាទ អាជ្ញាធរមូលដ្ឋាន ជំនាញជលផល អង្គការដៃគូ	កញ្ញា ២០២៥	សីហា ២០២៨

គ.៧- ផែនការកែលម្អកន្លែងសហគមន៍នេសាទ

ផែនការកែលម្អដែននេសាទ ត្រូវបានរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោម៖

ដែននេសាទ	ទំហំ (ហិកតា)	ទំហំដែលត្រូវកែលម្អ	សកម្មភាព	ប៉ាន់ប្រមាណតម្លៃ(ដុល្លារ)	ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម	ថ្ងៃ ខែ ឆ្នាំ បញ្ចប់
កន្លែងនេសាទសហគមន៍ជ្រោយស្វាយ	១៩៨	១៩៨ ហិកតា	ប្រជុំផ្សព្វផ្សាយដល់អង្គភាព អាជ្ញាធរ និងអ្នកពាក់ព័ន្ធ	១០០	កញ្ញា ២០២៥	សីហា ២០២៨
			សាងសង់ផ្ទាំងប៉ាណូផ្សព្វផ្សាយ ៣ផ្ទាំង ២,៥០ ម x ២ម គ្រឿងដែក(ដែកមូល)	៩០០		
			ស្លាកសញ្ញាផ្សព្វផ្សាយ ១០ផ្ទាំង១២០ស.ម x ១០០ស.ម គ្រឿងដែក(ដែកមូល)	៧០០		
			រៀបចំកែសម្រួលព្រំប្រទល់កន្លែងស.ន	១២០០		
			កំណត់ទីតាំងតាមនិយាមកានិងបោះបង្គោលព្រំប្រទល់សហគមន៍នេសាទលើគោក ៣០បង្គោល ធ្វើពីបេតុង សរសៃដែក	៤៥០០		
			បោះបង្គោលព្រំប្រទល់សហគមន៍នេសាទក្នុងទឹករាងសាជីកម្ពស់៩ ម៉ែត្រ ៣ បង្គោល	២៦០០		
ផ្លូវសហគមន៍នេសាទ 353800-1219202 353580-1219203 353580-1219215 353800-1219215	២២០ម x១២ម		ប្រជុំផ្សព្វផ្សាយដល់អង្គភាព អាជ្ញាធរ និងអ្នកពាក់ព័ន្ធ	១០០	កញ្ញា ២០២៥	សីហា ២០២៨
			រៀបចំឯកសារគាំទ្រពីអាជ្ញាធរ រដ្ឋបាលជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្ថានទូតជប៉ុន	៥០០		
			សាងសង់ផ្លូវ ទិញដី និងថ្មចាក់ផ្លូវ	២៥000		
			សាងសង់ទំនប់រលក ចតនាវានេសាទ	៥0000		

(ស.ន = សហគមន៍នេសាទ, ស.ម = សង្ហឹម៉ែត្រ, ម = ម៉ែត្រ)

គ.៨- ផែនការកំណត់និងរៀបចំកន្លែងអភិរក្សជលផលរបស់សហគមន៍នេសាទ

ផែនការកំណត់និងរៀបចំកន្លែងអភិរក្សជលផល ត្រូវរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោម៖

ឈ្មោះដែននេសាទ	ទំហំត្រូវអភិរក្ស (ហិកតា)	ប្រភេទនៃការអភិរក្ស	សកម្មភាព	ប៉ាន់ប្រមាណតម្លៃ(ដុល្លារ)	ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម	ថ្ងៃ ខែ ឆ្នាំ បញ្ចប់
អភិរក្សជលផលថ្មធំ ១១ ហិកតា 352741-1219648 352936-1219455 352948-1219342 352682-1219185	១១	-មច្ឆាជាតិ -ត្រីផ្សោត -ជីវចម្រុះ	ផ្សព្វផ្សាយពីកន្លែងអភិរក្សជលផលនិងហាមឃាត់ ឱ្យបានទូលំទូលាយ	៤៥០	កញ្ញា ២០២៥	សីហា ២០២៨
			ចុះរកទីតាំងជាក់ស្តែងតាមនិយាមកា	៣០០		
			បោះបង្គោលព្រំកន្លែងអភិរក្សជលផលធ្វើពីស៊ីម៉ង់ គ្រឿងដែក (សាជី) ចំនួន៤បង្គោល	៣៦០០		

352529-1219454						
អភិរក្សជលផល ពយអន្ទង់២៣ហិកតា 353336-1218656 353534-1218269 353474-1218000 353167-1217900 353060-1218422	២៣	-មច្ឆាជាតិ -ត្រីផ្សោត -ជីវចម្រុះ	ពង្រាយប្រអប់សិប្បនិម្មិតធ្វើពីបេតុង ចំនួន១៥០ប្រអប់	១៥000	កញ្ញា ២០២៥	សីហា ២០២៨
			ដាក់ស្លាកសញ្ញាចំនួន២ស្លាក	៣00		
			សង់ប៉មយាមការពារកន្លែងអភិរក្សជលផលភ្ជាប់ជាមួយបង្គោលធ្វើពីគ្រឿងឈើ ប្រក់ហ្វីប្រូស៊ីម៉ង់	៧00		
			ចុះសិក្សាប្រមូលព័ត៌មាន	៥00		
			ប្រជុំផ្សព្វផ្សាយពីកន្លែងសាងសង់ជម្រកសិប្បនិម្មិត	៥00		
អភិរក្សជលផល ពយចម្រុះ ១៩ហិកតា 353527-1215668 353288-1215477 352861-1216069 353034-1216202	១៩		ពង្រាយជម្រកត្រីសិប្បនិម្មិតធ្វើពីបេតុង ចំនួន៥0 កន្លែង	១៥000		

គ.៩- ផែនការកំណត់និងរៀបចំស្ថានីយ៍ភ្ញាស់កូនក្តាមសេះរបស់សហគមន៍នេសាទ

ផែនការកំណត់និងរៀបចំស្ថានីយ៍ភ្ញាស់កូនក្តាមសេះ ត្រូវរៀបចំឡើង ដើម្បីបង្កើនផលស្តុកធម្មជាតិនៃធនធានជលផល ដូចមាននៅក្នុងតារាងខាងក្រោម៖

ឈ្មោះដែននេសាទ	ទំហំ	ប្រភេទនៃការអភិរក្ស	សកម្មភាព	ប៉ាន់ប្រមាណតម្លៃ(ដុល្លារ)	ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម	ថ្ងៃ ខែ ឆ្នាំ បញ្ចប់
កន្លែងនេសាទសហគមន៍ជ្រោយស្វាយ នៅកំពង់ស្តាំ	សាកល្បងជំហានទី១ ៥0ម x ៥0ម	-ក្តាមសេះ -ជីវចម្រុះ	ផ្សព្វផ្សាយដល់ប្រជានេសាទឱ្យបានទូលំទូលាយដើម្បីប្រមូលក្តាមសេះពង	៣៦0	កញ្ញា ២០២៥	សីហា ២០២៨
			សាងសង់ស្ថានីយ៍១កន្លែង និងផែស្ថានីយ៍ធ្វើពីគ្រឿងឈើ ជើងបេតុង ស្រោបទុយោខៀវ ប្រក់ស័ង្កសីជ័រ និងសម្ភារជាង	១២000		
			រៀបចំបៃចំនួន២ បំប៉នមេក្តាមសេះធ្វើពីឈើគ្រាក់៨ដើម ឈើ១៨ដើម និងព័ទ្ធ សាច់អួន និងសម្ភារជាង	១000		
			ទិញសម្ភារ ឧបករណ៍ភ្ញាស់ក្តាមសេះ ចំនួន១ឈុត	១៩00		
			ដាក់ស្លាកសញ្ញាចំនួន២ស្លាក	២00		
			មូលនិធិក្តាមសេះ ប្រមូល និងថែទាំ	២000		
			ព្រលែងកូនក្តាម និងមេក្តាមពង	៥00		

(ម = ម៉ែត្រ)

ក.១០- ផែនការគ្រប់គ្រងព្រៃកោងកាង

ផែនការគ្រប់គ្រងកោងកាង ត្រូវបានរៀបចំឡើងវិញ ដូចមាននៅក្នុងតារាងខាងក្រោម៖

ឈ្មោះផែននេសាទ	ទំហំ (ហ.ត)	ប្រភេទព្រៃឈើការពារ	សកម្មភាព		ចំនួនប្រមាណតម្លៃ(ដុល្លារ)	ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម	ថ្ងៃ ខែ ឆ្នាំ បញ្ចប់
ព្រៃកោងកាងដែលមានស្រាប់ក្នុងកន្លែងសហគមន៍នេសាទ	៩	ព្រៃកោងកាង	ផ្សព្វផ្សាយពីកន្លែងព្រៃកោងកាងឱ្យទូលំទូលាយដល់ប្រជាពលរដ្ឋ	ប្រជុំ	៣០០	កញ្ញា ២០២៥	សីហា ២០២៨
				ចែកឯកសារ	១០០		
			បោះបង្គោលព្រំព្រៃកោងកាង ធ្វើពីបេតុង ២០ស.ម x ២០ស.ម x ២,៥ម ចំនួន២០ ដោយសរសេរអក្សរ ព្រំប្រទល់ព្រៃកោងកាង សហគមន៍នេសាទជ្រោយស្វាយ		២០០០		
			ដាក់ស្លាកសញ្ញាស្តីពីផែនទីព្រៃកោងកាង ២ ស្លាក ២,៥ម x ១,៥ម ធ្វើពីគ្រឿងដែក ចាក់បេតុង		៨០០	កញ្ញា ២០២៥	សីហា ២០២៨
			ថែរក្សា ការពារ				
វាលភក់ស្ថិតក្នុងកន្លែងនេសាទសហគមន៍ ១០៩ហិកតា	១០៩	ព្រៃកោងកាង	ផ្សព្វផ្សាយពីកន្លែងព្រៃកោងកាងឱ្យទូលំទូលាយដល់ប្រជាពលរដ្ឋ	ប្រជុំ	៣០០	កញ្ញា ២០២៥	សីហា ២០២៨
				ចែកឯកសារ	១០០		
			រកចំណុចទីតាំងជាក់ស្តែងតាមនិយាមកា		២០០		
			ដាក់ស្លាកសញ្ញាស្តីពីផែនទីព្រៃកោងកាង ២ ស្លាក ២,៥ម x ១,៥ម ធ្វើពីគ្រឿងដែក ចាក់បេតុង		៨០០		
			រៀបចំថ្នាលបណ្តុះកូនកោងកាង បង្គោលឈើ និងស្បែ ១០ម x ២០ម		១០០០		
			បណ្តុះ ដាំ និងថែទាំដើមកោងកាងចំនួន ១៩ ហិកតា (១ហិកតាx៧០០០ដើម)		១៣៣០០០		
			ដាំកូនកោងកាងចំនួន១៥នាក់x៨,៥ ដុល្លារ/ថ្ងៃ		៦០០០		
			ថែទាំដើមកោងកាង រយៈពេល៣ខែ ៤នាក់ x ១០ដុល្លារ/ថ្ងៃ,២ថ្ងៃ/អាទិត្យ		១០០០		
			ពី៣ខែដល់៦ខែ ៤នាក់ x ១០ដុល្លារ/ថ្ងៃ, ១ថ្ងៃ/អាទិត្យ		១០០០		
			ពី៦ខែឡើងទៅ ៤នាក់x១០ដុល្លារ/ថ្ងៃ,១ថ្ងៃ/ខែ		១២០០		

(ស.ម = សង្ហឹមែ៉ត្រ, ម = ម៉ែ៉ត្រ)

ផ្នែកទី២. សេដ្ឋកិច្ចនិងការអភិវឌ្ឍន៍សហគមន៍នេសាទ

គ១១- ផែនការបង្កើនមុខរបរសមាជិកក្នុងសហគមន៍នេសាទ

ផែនការបង្កើនមុខរបរសមាជិកក្នុងសហគមន៍នេសាទ ត្រូវបានរៀបចំឡើងដូចខាងក្រោម៖

សកម្មភាព	លទ្ធផលរំពឹងទុក	ប៉ាន់ប្រមាណតម្លៃ (ដុល្លារ)	អ្នកចូលរួម	ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម	ថ្ងៃ ខែ ឆ្នាំ បញ្ចប់
១.ផែនការបណ្តុះបណ្តាល					
ចិញ្ចឹមគ្រែងឈាម	-មានចំណេះដឹងក្នុងការចិញ្ចឹម -យកទៅអនុវត្តជាក់ស្តែងបាន - សមាជិកនិងគណៈកម្មការស.ន ទទួលបានចំណេះដឹងលើគុណភាពទឹក តាមរយៈការចូលរួមវគ្គបណ្តុះបណ្តាលស្តីពីជាតិពុលក្នុងទឹក ការពិនិត្យគុណភាពទឹក ការតាមដាន និងរាយការណ៍ -ការអនុវត្តសាកល្បងលើការចិញ្ចឹមដោយមិនប្រើចំណី។	៩០០	គណៈកម្មការនិងសមាជិកស.ន	កញ្ញា ២០២៥	សីហា ២០២៨
ចិញ្ចឹមក្តាមថ្ម ក្តាមសេះ		៩០០	គណៈកម្មការនិងសមាជិកស.ន		
ចិញ្ចឹមងាវភក់		៩០០	គណៈកម្មការនិងសមាជិកស.ន		
ចិញ្ចឹមត្រីឆ្តង់ តុកកែ កង្កែប និងចិញ្ចឹមអន្ទង់	-មានចំណេះដឹង -មានសុវត្ថិភាពចំណីអាហារ -មានជម្រើសមុខរបរ -បង្កើនប្រាក់ចំណូល	១០០០	គណៈកម្មការនិងសមាជិកស.ន	កញ្ញា ២០២៥	សីហា ២០២៨
កែច្នៃផលនេសាទ		៩០០			
បច្ចេកទេសដាំបន្លែ		៩០០			
បច្ចេកទេសកសិកម្មចម្រុះ និងកសិកម្មបន្ត		៩០០			
ការនេសាទខ្នាតមធ្យមនៅកន្លែងនេសាទសាធារណៈ	-មានចំណេះដឹងនេសាទខ្នាតមធ្យម -មានជម្រើសមុខរបរបន្ថែម	៩០០	គណៈកម្មការនិងសមាជិកស.ន	កញ្ញា ២០២៥	សីហា ២០២៨
ការនេសាទខ្នាតធំនៅសមុទ្រខាងក្រៅ ឬសមុទ្រអន្តរជាតិ	-មានចំណេះដឹងនេសាទខ្នាតមធ្យម -មានជម្រើសមុខរបរបន្ថែម	៣០០០	គណៈកម្មការនិងសមាជិកស.ន	កញ្ញា ២០២៥	សីហា ២០២៨
បច្ចេកទេសកំណត់អាទិភាពជម្រើសមុខរបរ	-មានចំណេះដឹង -មានមុខរបរខ្នាតតូច ឬសិប្បកម្ម -បង្កើនប្រាក់ចំណូល	៩០០	គណៈកម្មការនិងសមាជិកស.ន	កញ្ញា ២០២៥	សីហា ២០២៨
ជំនាញវិជ្ជាជីវៈលើការផ្តល់សេវាទេសចរណ៍ជលផល	-ក្រុមចុងភៅ -ក្រុមផ្ទះស្នាក់នៅ -ក្រុមដឹកជញ្ជូន -ក្រុមផ្ទៃរយានយន្ត -ក្រុមឧបករណ៍នេសាទ -ក្រុមកែច្នៃផល ផលិតផលជលផល -ក្រុមផ្គត់ផ្គង់ផលកសិកម្ម -ក្រុមរោងលម្ហែ (កញ្ចុះ)	១០០០	គណៈកម្មការនិងសមាជិស.ន	កញ្ញា ២០២៥	សីហា ២០២៨
២.ទស្សនៈកិច្ចសិក្សា		៦៨០០	គណៈកម្មការនិងសមាជិស.ន		

៣.ផែនការបង្កើតក្រុមមុខរបរ						
ក្រុមចិញ្ចឹមគ្រែងឈាម ក្រុមចិញ្ចឹមក្តាមថ្ម ក្តាមសេះ ក្រុមចិញ្ចឹមងាវភក់	-មានក្រុមចិញ្ចឹមគ្រែងឈាម ក្តាមថ្ម និងងាវភក់ -មានគ្រែងឈាម តាមថ្ម និងងាវភក់ផ្គត់ផ្គង់ទីផ្សារ -មានមុខរបរនិងប្រាក់ចំណូល	៥00	គណៈកម្មការនិង សមាជិស.ន	កញ្ញា ២០២៥	សីហា ២០២៨	
ក្រុមចិញ្ចឹមត្រីឆ្គង់ តុកកែ កង្កែប និងអន្ទង់	-មានក្រុមចិ.ត្រីឆ្គង់ តុកកែ កង្កែប និងចិញ្ចឹមអន្ទង់ -មានបន្លែផ្គត់ផ្គង់ដល់កន្លែងកំសាន្តនិងទីផ្សារ -មានមុខរបរនិងប្រាក់ចំណូល	១000	គណៈកម្មការនិង សមាជិស.ន	កញ្ញា ២០២៥	សីហា ២០២៨	
ក្រុមកែច្នៃផលនេសាទ ដោយផ្តោតលើ ៖ -ក្រុមស្ត្រី -ជនងាយរងគ្រោះក្នុងស.ន	-មានក្រុមកែច្នៃផលនេសាទ -មានផលិតផលផលផលផ្គត់ផ្គង់ដល់កន្លែងកំសាន្តនិងទីផ្សារ -មានមុខរបរនិងប្រាក់ចំណូល	៥00	គណៈកម្មការនិង សមាជិស.ន	កញ្ញា ២០២៥	សីហា ២០២៨	
ក្រុមដាំបន្លែ	-មានក្រុមដាំបន្លែ -មានបន្លែផ្គត់ផ្គង់តម្រូវការ -មានមុខរបរនិងប្រាក់ចំណូល	៥00	គណៈកម្មការនិង សមាជិស.ន	កញ្ញា ២០២៥	សីហា ២០២៨	
ក្រុមកសិកម្មចម្រុះ និង កសិកម្មបន្ត	-មានក្រុមកសិកម្មចម្រុះនិងបន្ត -មានដំណាំចម្រុះផ្គត់ផ្គង់តម្រូវការ -មានមុខរបរនិងប្រាក់ចំណូល	៥00	គណៈកម្មការនិង សមាជិស.ន	កញ្ញា ២០២៥	សីហា ២០២៨	
ក្រុមអ្នកនេសាទខ្នាតមធ្យម នៅកន្លែងនេសាទសាធារណៈ	-មានចំណេះដឹងនេសាទខ្នាតមធ្យម -មានផលនេសាទបន្ថែមពីខាងក្រៅ -មានមុខរបរ បង្កើនប្រាក់ចំណូល	៣000	គណៈកម្មការនិង សមាជិស.ន	កញ្ញា ២០២៥	សីហា ២០២៨	
ក្រុមនេសាទខ្នាតធំនៅសមុទ្រខាងក្រៅ ឬសមុទ្រអន្តរជាតិ		១៥0000				

(ស.ន = សហគមន៍នេសាទ)

គ១២-ផែនការអភិវឌ្ឍន៍វារីវប្បកម្មក្នុងសហគមន៍នេសាទ

ផែនការសម្រាប់អភិវឌ្ឍន៍វារីវប្បកម្មក្នុងសហគមន៍ ត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

ប្រភេទវារីវប្បកម្ម	ចំនួន	ប្រភេទកូនត្រីពូជ	បរិមាណកូនត្រីពូជ	ប៉ាន់ស្មានតម្លៃ(ដុល្លារ)	ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម	ថ្ងៃ ខែ ឆ្នាំ ប្រមូលផល
ចិញ្ចឹមកង្កែប អន្ទង់ តាមអាង ឬតង់ (៤គ្រួសារ)	២តង់x២ម x១,៥ម x១,២ម	អន្ទង់	៣ ៦00	៧២0	កញ្ញា ២០២៥	សីហា ២០២៨
